ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
CAMBODIAN NATIONAL COUNCIL FOR CHILDREN

លេខ...១៤០....ក.ជ.ក.ក

ភ្នំពេញ ថ្ងៃទី ២៨ ខែ ៧ ឆ្នាំ ២០០០

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធទៅនឹងកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

***********

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- យោងតាមប្រការ ៤ នៃអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៩ និងយោងតាមតំរូវការចាំបាច់នាពេលបច្ចុប្បន្ន ។

## សំរេច

**ប្រការ ១** : បង្កើតអនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធទៅនឹងកុមារ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងគោលបំណង ពិនិត្យសិក្សាស្រាវជ្រាវ រៀបរៀងសេចក្តីព្រាងច្បាប់ ដើម្បីការពារ និង អភិវឌ្ឍន៍កុមារ និង ដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

**ប្រការ ២** : អនុគណៈកម្មការនេះ អនុវត្តការងាររបស់ខ្លួន ក្រោមការដឹកនាំរបស់ប្រធានអនុគណៈកម្មការ និង សំរបសំរួលដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។

**ប្រការ ៣** : សមាសភាពអនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធទៅនឹងកុមារមាន :

| | | |
|---|---|---|
| ១- | ឯកឧត្តម រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | ជា ប្រធាន |
| ២- | ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ជា អនុប្រធាន |
| ៣ - | លោកជំទាវអនុប្រធាន ក.ជ.ក.កតំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជា អនុប្រធាន |
| ៤ - | លោកប្រធានគណៈមេធាវី | ជា អនុប្រធាន |
| ៥ - | មន្ត្រីតំណាងក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី | ជា សមាជិក |
| ៦ - | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ជា សមាជិក |
| ៧ - | មន្ត្រីជំនាញច្បាប់ តំណាងក្រសួងយុត្តិធម៌ | ជា សមាជិក |
| ៨ - | មន្ត្រីជំនាញច្បាប់ តំណាងក្រសួងមហាផ្ទៃ | ជា សមាជិក |
| ៩ - | មន្ត្រីជំនាញ តំណាងក្រសួងអប់រំយុវជន និង កីឡា | ជា សមាជិក |
| ១០ - | លោកស្រីសមាជិក ក.ជ.ក.កតំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | ជា សមាជិក |
| ១១ - | លោកសមាជិក ក.ជ.ក.កតំណាងក្រសួងការពារជាតិ | ជា សមាជិក |
| ១២ - | មន្ត្រីជំនាញច្បាប់ តំណាងអង្គការយូនីសេហ្វ | ជា សមាជិក |
| ១៣- | មន្ត្រីជំនាញច្បាប់ នៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា | ជា សមាជិក |
| ១៤ - | មន្ត្រីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) | ជា សមាជិក |

**ប្រការ ៤** : អនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធទៅនឹងកុមារ មានភារកិច្ចដូចតទៅ :

- ពិនិត្យឡើងវិញនូវច្បាប់ដែលមានស្រាប់ សេចក្តីព្រាងច្បាប់ ដើម្បីរកនូវចំណុចខ្វះខាតដែល ពាក់ព័ន្ធទៅ នឹងសិទ្ធិកុមារ និង ផ្តល់អនុសាសន៍ជារួមជូន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។
- ចូលរួមធ្វើសេចក្តីព្រាងច្បាប់ កែសំរួលច្បាប់ ឬ បទបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធទៅ នឹងសិទ្ធិកុមារ ។
- ធ្វើសេចក្តីព្រាងច្បាប់សំរាប់កុមារ ក្នុងករណីចាំបាច់ ។
- សហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និង អង្គការអភិវឌ្ឍន៍ ។